# សង្ខេបរបាយការណ៍ ឧបតិហេតុ និងការយាយី អ្នកសារព័ត៌មាន

នៅឆមាសទីមួយនៃឆ្នាំ២០២៥

**ការគំរាមកំហែងពីវិធានការផ្លូវច្បាប់មានចំនួន០២ករណី**

**គំរាមកំហែងដោយពាក្យសម្ដីមានចំនួន០១ករណី**

**១៧ ករណី**

**ការបំភិតបំភ័យមានចំនួន០៩ករណី**

**ការឃាត់ខ្លួនមានចំនួន០៣ករណី**

**ការបៀតបៀនមកលើអ្នកសារព័ត៌មានមានចំនួន០២ករណី**

# សង្ខេបរបាយការណ៍ ឧបតិហេតុ និងការយាយី អ្នកសារព័ត៌មាន

នៅឆមាសទីមួយនៃឆ្នាំ២០២៥

**ជាផ្នែកមួយនៃការគាំទ្រផ្នែកច្បាប់សម្រាប់អ្នកសារព័ត៌មាន និងការតស៊ូមតិដើម្បីលើកកម្ពស់សុវត្ថិភាពដល់អ្នកសារព័ត៌មាន មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ហៅកាត់ថា ស៊ីស៊ីអាយអឹម ឃ្លាំមើល និងកត់ត្រាឧបតិហេតុ និងការយាយីលើអ្នកសារព័ត៌មាននៅប្រទេសកម្ពុជា។ ការគាំទ្រផ្នែកច្បាប់ និងការឃ្លាំមើលឧបតិហេតុ និងការយាយីលើអ្នកសារព័ត៌មាននេះមានសារៈសំខាន់ ដោយសារបញ្ហាទាំងនេះនៅតែបន្តកើតមានលើអ្នកសារព័ត៌មាន ។**

នៅក្នុងឆមាសទី១នៃឆ្នាំ២០២៥ បរិយាកាសប្រព័ន្ធផ្សព្វផ្សាយនៅតែ**បង្កជាឧបសគ្គ**សម្រាប់អ្នកសារព័ត៌មានដែលហ៊ានរាយការណ៍ប្រធានបទរសើប។ អ្នកសារព័ត៌មានដែលហ៊ានរាយការណ៍អំពី វិវាទដីធ្លី បញ្ហាបរិស្ថាន និងអភិបាលកិច្ចមូលដ្ឋាន ជារឿយៗប្រឈមមុខនឹងសម្ពាធផ្នែកច្បាប់ និងសម្ពាធពីអាជ្ញាធរនៅក្នុងមូលដ្ឋាន។ បទញុះញង់ និងបរិហារកេរ្តិ៍ត្រូវបានប្រើប្រាស់ជាមធ្យោបាយទប់ស្កាត់ការរាយការណ៍ព័ត៌មានដែលមានលក្ខណៈវិភាគឬរិះគន់។

ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២៥ ស៊ីស៊ីអាយអឹម បានកត់




ក្នុងនោះមានអ្នកសារព័ត៌មានអាជីព អ្នកសារព័ត៌មានពលរដ្ឋ និងអ្នកសារព័ត៌មានវ័យក្មេងសរុបចំនួន២២នាក់។




ករណីទាំងនោះរួមមាន ការចាប់ខ្លួនដោយគ្មានដីកា ការគំរាមកំហែងពីវិធានការតាមផ្លូវច្បាប់ ការបំភិតបំភ័យ និងការស្នើសុំឱ្យលុបអត្ថបទចេញ ឬកែសម្រួលខ្លឹមសារដែលបានបោះពុម្ពផ្សាយ ព្រមទាំងមានករណីដកអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយចំនួនបីផងដែរ។ ក្នុងនោះមានករណីមួយដែលមន្ត្រីមូលដ្ឋានបានមកចូលមកដោយគ្មានការអនុញ្ញាតិពីអ្នករៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកសារព័ត៌មាន ដោយមន្ត្រីរូបនោះបានកត់ត្រាព័ត៌មានអ្នកចូលរួម និងសាកសួរអ្នករៀបចំអំពីខ្លឹមសារនៃវគ្គបណ្តុះបណ្តាល។ ហេតុការណ៍ទាំងនេះជាសញ្ញាណនៃការបង្កើនការព្រួយបារម្ភដល់សេរីភាពសារព័ត៌មាន និងបង្ហាញពីតម្រូវការសម្រាប់ការការពារ និងបរិយាកាសគាំទ្របន្ថែមទៀតសម្រាប់អ្នកធ្វើការក្នុងវិស័យសារព័ត៌មាននៅទូទាំងប្រទេស ។

## ឧបតិហេតុសំខាន់ៗ៖

ក្នុងឧបតិហេតុនិងការយាយីទាំង១៧ករណី ការបៀតបៀនមកលើអ្នកសារព័ត៌មានមានចំនួន០២ករណី ការបំភិតបំភ័យមានចំនួន០៩ករណី ការគំរាមកំហែងពីវិធានការផ្លូវច្បាប់មានចំនួន០២ករណី ការឃាត់ខ្លួនមានចំនួន០៣ករណី និង គំរាមកំហែងដោយពាក្យសម្តីមានចំនួន០១ករណី ។ ករណីទាំងនេះកើតឡើងបន្ទាប់ពីពួកគេរាយការណ៍ពាក់ព័ន្ធនឹងការស៊ើបអង្កេតលើការកាប់ឈើខុសច្បាប់នៅក្នុងដែនជម្រកសត្វព្រៃឡង់ ការការពារព្រៃឈើនៅក្នុងសហគមន៍ ដីសម្បទាន ជម្លោះដីធ្លីរវាងក្រុមហ៊ុនឯកជនជាមួយប្រជាពលរដ្ឋ និងការផ្សាយពីបញ្ហាផ្លូវសាធារណៈដែលបានខូចជាញឹកញាប់ជាដើម។



# សង្ខេបរបាយការណ៍ ឧបតិហេតុ និងការយាយី អ្នកសារព័ត៌មាន

នៅឆមាសទីមួយនៃឆ្នាំ២០២៥

ក្នុងនោះ ករណីដ៏លេចធ្លោមួយគឺការចាប់ខ្លួនអ្នកកាសែតបរិស្ថានគឺ**លោក អ៊ុក ម៉ៅ** ដែលមានមូលដ្ឋាននៅខេត្តស្ទឹងត្រែង។ លោកត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ១៦ ឧសភា ដោយគ្មានដីការនៅក្នុងផ្ទះរបស់គាត់។ លោក អ៊ុក ម៉ៅ គឺជាអ្នកសកម្មម្នាក់ដែលរាយការណ៍អំពីការកាប់ឈើខុសច្បាប់នៅក្នុងតំបន់នោះតាំងពីឆ្នាំ២០១៧មកម្ល៉េះ។

ភាពសកម្មក្នុង**ការរាយការណ៍បទល្មើសព្រៃឈើ** បានបណ្ដាលអោយលោកអ៊ុក ម៉ៅត្រូវបានចាប់ខ្លួនជាច្រើនលើកពីបទញុះញង់។ បច្ចុប្បន្ននេះ លោកត្រូវប្រឈមមុខនឹងសំណុំរឿងផ្លូវច្បាប់ចំនួន១៥ករណី ហើយត្រូវបានដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ។

លោកត្រូវបានដោះលែងឲ្យនៅក្រៅឃុំកាលពីថ្ងៃទី ២៥ ខែឧសភា បន្ទាប់ពីជាប់ពន្ធនាគារជាច្រើនថ្ងៃនៅពន្ធនាគារខេត្តស្ទឹងត្រែង។

បន្ថែមពីលើនេះ ស៊ីស៊ីអាយអឹមក៏បានសង្កេតឃើញមានការបំភិតបំភ័យអ្នកសារព័ត៌មានពលរដ្ឋចំពោះការរាយការណ៍របស់ពួកគេផងដែរ។





## ករណីសំខាន់ៗរួមមាន៖

**ករណីទី១៖** ស្រ្តីពលរដ្ឋអ្នកសារព័ត៌មាននៅខេត្តស្ទឹងត្រែងប្រឈមមុខនឹង**ការគំរាមកំហែងពីអាជ្ញាធរមូលដ្ឋាន**ជុំវិញសេចក្ដីរាយការណ៍ជាវីដេអូអំពីភាពអសកម្មរបស់អាជ្ញាធរមូលដ្ឋានក្នុងការជួសជុលផ្លូវមួយខ្សែក្នុងសហគមន៍ ដែលរងការខូចខាត និងបង្កផលប៉ះពាល់ដល់ជីវភាពរបស់សហគមន៍។ បន្ទាប់ពីចេញផ្សាយព័ត៌មាននេះ អាជ្ញាធរមូលដ្ឋានបានព្រមានប្រភពដែលបានផ្ដល់បទសម្ភាសន៍នៅក្នុងវីដេអូ ហើយបានទៅដល់ផ្ទះរបស់ពលរដ្ឋអ្នកសារព័ត៌មាន ដោយថតរូបគាត់ ថតផ្ទះ និងថតរូបសមាជិកគ្រួសារ។

**ករណីទី២៖** ពលរដ្ឋអ្នកសារព័ត៌មានម្នាក់នៅខេត្តកំពង់ធំ បានរាយការណ៍ជាវីដេអូអំពីភាពយឺតយ៉ាវរបស់ការិយាល័យច្រកចេញចូលតែមួយនៅស្រុកមួយក្នុងខេត្តកំពង់ធំ។ បន្ទាប់ពីចេញផ្សាយព័ត៌មានជាវីដេអូ **ពលរដ្ឋអ្នកសារព័ត៌មានត្រូវបានគេហៅទៅជួបក្រៅផ្លូវការជាមួយមន្ត្រីអាជ្ញាធរស្រុកម្នាក់** ដែលបានសួរនាំគាត់លម្អិតអំពីអ្វីដែលប្រភពបានផ្ដល់ក្នុងបទសម្ភាសន៍ព័ត៌មាន ហើយមន្ត្រីអាជ្ញាធរថែមទាំងសុំឱ្យលុបវីដេអូចេញពីទំព័រហ្វេសប៊ុក ព័ត៌មានពលរដ្ឋ។

**ករណីទី៣៖** ពលរដ្ឋអ្នកសារព័ត៌មានម្នាក់ទៀតនៅខេត្តពោធិ៍សាត់បានរាយការណ៍អំពីជម្លោះដីធ្លីដ៏ចម្រូងចម្រាស់នៅខេត្តកំពង់ឆ្នាំង ដែលប្រជាពលរដ្ឋរស់នៅក្បែរតំបន់បឹងទន្លេសាបបានចោទប្រកាន់ថា អាជ្ញាធរថា បានបែងចែកដីរបស់ពួកគេឱ្យទៅអ្នកចំណាកស្រុកមកពីខេត្តផ្សេងៗ។ បន្ទាប់ពីការផ្សាយព័ត៌មាននេះ **មន្ទីរព័ត៌មានខេត្តកំពង់ឆ្នាំងបានចេញលិខិតបំភ្លឺ**មួយ ដោយអះអាងថា ព័ត៌មានដែលបានចេញផ្សាយនេះ គឺមិនពិត លំអៀង និងគ្មានប្រភពច្បាស់លាស់ ប៉ុន្តែមិនបានបញ្ជាក់នៅចំណុចត្រង់ណាដែលមិនពិត ឬមានកំហុងឆ្គងឡើយ។ ពលរដ្ឋអ្នកសារព័ត៌មានក៏រងការព្រមានដោយផ្ទាល់មាត់ពីជនមិនស្គាល់អត្តសញ្ញាណ ដោយថែមទាំងគំរាមមិនឱ្យចេញផ្សាយព័ត៌មាននេះតទៅទៀត។

# សង្ខេបរបាយការណ៍ ឧបតិហេតុ និងការយាយី អ្នកសារព័ត៌មាន

នៅឆមាសទីមួយនៃឆ្នាំ២០២៥





យើងសង្ឃឹមថានៅក្នុងឆ្នាំ២០២៥នេះ ករណីដែលពាក់ព័ន្ធនឹងការគំរាមកំហែង ឬការដាក់សម្ពាធលើអ្នកសារព័ត៌មាននឹងមានការថយចុះ។ ការយល់ដឹងរបស់អាជ្ញាធរមានសមត្ថកិច្ចអំពីតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ នឹងចូលរួមកាត់បន្ថយភាពតានតឹង និងជួយធ្វើឱ្យកិច្ចសហប្រតិបត្តិការកាន់តែប្រសើរឡើង។ នៅពេលដែលអ្នកសារព័ត៌មានអាចរាយការណ៍ដោយសេរី និងទទួលខុសត្រូវ វានឹងពង្រឹងលទ្ធភាពទទួលបានព័ត៌មាន និងការជឿទុកចិត្តពីសាធារណៈជន។

ស៊ីស៊ីអាយអឹម នឹងបន្តឃ្លាំមើលស្ថានការណ៍ ផ្តល់ការគាំទ្រផ្នែកច្បាប់ និងធ្វើការដើម្បីលើកកម្ពស់សុវត្ថិភាពសម្រាប់បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយទាំងអស់នៅក្នុងប្រទេសកម្ពុជា។

ដើម្បីលើកកម្ពស់សុវត្ថិភាពអ្នកសារព័ត៌មាន ស៊ីស៊ីអាយអឹម នឹងបន្តឃ្លាំមើលឧបតិហេតុ និងការយាយីលើអ្នកសារព័ត៌មាន និងផ្តល់**ការគាំទ្រលើសេវាផ្នែកច្បាប់ និងការអន្តគមន៍**។ សូមទាក់ទងមកយើងខ្ញុំតាមរយៈលេខទូរស័ព្ទ ០៦០ ៥០ ៥០ ៥០ ដើម្បីរាយការណ៍ពីករណីយាយីដែលកើតមានលើអ្នកឬដើម្បីស្នើសុំជំនួយឬការប្រឹក្សាផ្នែកច្បាប់។

បុគ្គលិករបស់ស៊ីស៊ីអាយអឹមក៏បានជួបប្រទះ**ការឃ្លាំមើលពីអាជ្ញាធរមូលដ្ឋាន**នៅពេលចុះអនុវត្តសកម្មភាព គម្រោង។ មន្ត្រីអាជ្ញាធរមូលដ្ឋានម្នាក់បានចុះទៅពិនិត្យវគ្គបណ្តុះបណ្តាលដែលអង្គការស៊ីស៊ីអាយអឹមរៀបចំសម្រាប់អ្នកសារព័ត៌មានមួយក្រុមនៅក្នុងខេត្តក្រចេះ។

មន្ត្រីអាជ្ញាធរមូលដ្ឋានបានថតរូបវគ្គបណ្តុះបណ្តាល បញ្ជីឈ្មោះអ្នកចូលរួម កត់ត្រាឈ្មោះបុគ្គលិក និងលេខទូរស័ព្ទ ហើយបានសាកសួរអំពីខ្លឹមសារនៃវគ្គបណ្តុះបណ្តាល។

ឧបតិហេតុនិងការយាយីលើអ្នកសារព័ត៌មាននេះបានធ្វើឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីសេរីភាពសារព័ត៌មាន និងសុវត្ថិភាពអ្នកសារព័ត៌មាន ដែលរំខានដល់ការងាររបស់ពួកគេ និងរារាំងព័ត៌មានពិតមិនបានផ្សព្វផ្សាយទៅដល់សាធារណៈជន។

